នស/រកត/០៦០៦/២៧៥

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការបង្កើតអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/ ០៣០៥/ ០០៥ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០០៦

# ព្រះរាជក្រឹត្យ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ហៅកាត់ថា " **អាជ្ញាធរជាតិ អាវុធគីមី** " ឬ " **អ.ជ.អ.គ** " ដើម្បីធ្វើជាចំណុចប្រសព្វរបស់ជាតិ ក្នុងការទាក់ទងឱ្យមានប្រសិទ្ធភាពជាមួយអង្គការនិងជាមួយរដ្ឋជាភាគីដទៃទៀត និង ដើម្បីគ្រប់គ្រងទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និង វិទ្យុសកម្ម ។

## ជំពូកទី ២

## សមាសភាព

**មាត្រា ២.-**

**អ.ជ.អ.គ** មានសមាសភាពដូចតទៅ ÷

- រដ្ឋមន្ត្រីក្រសួងការពារជាតិ — ប្រធាន
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋលេខាធិការ ០១រូប — អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬរដ្ឋលេខាធិការ ០១រូប — អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬរដ្ឋលេខាធិការ ០១រូប — អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬរដ្ឋលេខាធិការ ០១រូប — អនុប្រធាន
- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ០១រូប — សមាជិក
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬរដ្ឋលេខាធិការ ០១រូប — សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬរដ្ឋលេខាធិការ ០១រូប — សមាជិក
- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬរដ្ឋលេខាធិការ ០១រូប — សមាជិក
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬរដ្ឋលេខាធិការ ០១រូប — សមាជិក
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬរដ្ឋលេខាធិការ ០១រូប — សមាជិក
- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឬរដ្ឋលេខាធិការ ០១រូប — សមាជិក
- ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ — សមាជិក
- អគ្គមេបញ្ជាការ ឬអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ០១រូប — សមាជិក
- អគ្គស្នងការ ឬអគ្គស្នងការរងនគរបាលជាតិ ០១រូប — សមាជិក

- អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេសក្រសួងការពារជាតិ សមាជិក
- មេបញ្ជាការ ឬមេបញ្ជាការរងនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស ០១រូប សមាជិក។

**មាត្រា ៣.-**

អ.ជ.អ.គ មានសិទ្ធិទាក់ទងបន្ថែមជាមួយក្រសួង ស្ថាប័ននានា ដែលពុំមានចែងក្នុងមាត្រា ២ ខាងលើនេះ និងអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ប្រទេសនានាទៀត តាមការចាំបាច់ ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍តាមការអញ្ជើញរបស់ប្រធាន។

## ជំពូកទី ៣
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អ.ជ.អ.គ

**មាត្រា ៤.-**

អ.ជ.អ.គ មានតួនាទីដូចតទៅ ÷

- គ្រប់គ្រងរាល់សកម្មភាពទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ
- ជាស្ថាប័នជាតិតែមួយគត់តំណាងឱ្យរាជរដ្ឋាភិបាល នូវរាល់កិច្ចប្រជុំអន្តរជាតិស្តីពីការទប់ស្កាត់ការរីកសាយ អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា ក្នុងការចរចា និងចុះហត្ថលេខា តាមការប្រទានសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល ជាមួយអង្គការអន្តរជាតិ ឬរដ្ឋជាភាគីលើអនុសញ្ញា ពិធីសារ ឬកិច្ចព្រមព្រៀងនានាពាក់ព័ន្ធនឹងអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- តំណាងឱ្យរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើអនុស្សរណៈ កិច្ចសន្យា គម្រោងទាំងឡាយ តាមការប្រទានសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល នៃជំនួយទ្វេភាគី និងពហុភាគី ដើម្បីទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ។

**មាត្រា ៥.-**

អ.ជ.អ.គ មានមុខងារ និងភារកិច្ចដូចតទៅ ÷

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព ក្នុងការគ្រប់គ្រង ទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- ផ្សព្វផ្សាយ ធានាការអនុវត្ត និងតាមដានត្រួតពិនិត្យរាល់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលរាជរដ្ឋាភិបាលបានសម្រេច

-សហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ឬរដ្ឋជាភាគីក្នុងការអនុវត្តអនុសញ្ញា កិច្ចព្រមព្រៀង ដែលពាក់ព័ន្ធនឹងអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

- ចាត់វិធានការនានា ដើម្បីគ្រប់គ្រង ទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ អង្គភាពរដ្ឋនានា គ្រឹះស្ថាន និងក្រុមហ៊ុនឯកជននានា ដើម្បីចេញកំណត់ការនាំចេញ នាំចូល ការឆ្លងកាត់សារធាតុគីមី និងជីវសាស្ត្រ និងសារធាតុទាក់ទងនឹងនុយក្លេអ៊ែរ និងវិទ្យុសកម្ម

- តាមដាន និងត្រួតពិនិត្យការងារនៃការទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និង វិទ្យុសកម្ម

- សម្របសម្រួលរាល់សកម្មភាពទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

- កៀរគរប្រភពធនធាន ជំនួយបច្ចេកទេស អាហារូបករណ៍ និងហិរញ្ញវត្ថុ ក្នុង និងក្រៅប្រទេស

-គ្រប់គ្រងការអនុវត្តច្បាប់ និងអនុសញ្ញានានាទាក់ទងនឹងការទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

- ផ្តល់យោបល់ និងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

**មាត្រា ៦.-**

**អ.ជ.អ.គ** ត្រូវប្រជុំយ៉ាងហោចណាស់ ២លើក ក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីចាំបាច់ប្រធាន **អ.ជ.អ.គ** អាចអញ្ជើញក្រសួង ស្ថាប័ន ឬបុគ្គលដែលពាក់ព័ន្ធឱ្យចូលរួមប្រជុំបាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចដឹកនាំការប្រជុំជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន ។

**មាត្រា ៧.-**

**អ.ជ.អ.គ** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានទីតាំងនៅក្រសួងការពារជាតិ ។ ក្នុងករណីចាំបាច់ ទីតាំងនេះអាចផ្លាស់ប្តូរបាន ។

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

**មាត្រា ៨.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ជ.អ.គ** ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៩.-**

**អ.ជ.អ.គ** មានសិទ្ធិប្រើប្រាស់ត្រាផ្ទាល់របស់ខ្លួន ។

## ជំពូកទី ៤
## ធនធាន និងថវិកា

**មាត្រា ១០.-**

ដើម្បីដំណើរការការងាររបស់ខ្លួន **អ.ជ.អ.គ** ត្រូវមានខ្ទង់ថវិកាភ្ជាប់ទៅនឹងកញ្ចប់ថវិការបស់ក្រសួងការពារជាតិ ។

**អ.ជ.អ.គ** អាចទទួលថវិកា និងទ្រព្យសម្បត្តិពី ÷

- ថវិកាជាតិ
- ជំនួយពីសហគមន៍អន្តរជាតិ និងអង្គការអន្តរជាតិនានា
- សប្បុរសជន
- ការរឹបអូសរបស់តុលាការ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង . រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០០៦

នស/រកត/០៦០៦/២៩៥ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ៦៩៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃួន ជិនកេន**